# សំណើយុទ្ធសាស្ត្រដើម្បីប្រើប្រាស់សក្តានុពលនៃផលិតកម្មស្រូវនៅកម្ពុជា

**អត្ថបទពិភាក្សារបស់អង្គការសេដាក[១] លើវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ ខែ មិថុនា ឆ្នាំ ២០០៨**

**ដោយបណ្ឌិត យ៉ង សាំងកុមារ ( អង្គការ សេដាក )[២]**

## ១. សេចក្តីផ្តើម

ដំណាំស្រូវ គឺជាដំណាំអាហារដ៏មានសារៈសំខាន់បំផុត សម្រាប់ប្រជាជនកម្ពុជា ហើយប្រជាជនយើងប្រមាណជា ៦០ ទៅ ៦៥ % ( ប្រទេសកម្ពុជាមានប្រជាជនសរុបចំនួន ១៤ លាននាក់) ពាក់ព័ន្ធទៅនឹងការធ្វើស្រែ ឬមានមុខ របរចិញ្ចឹមជីវិតអាស្រ័យលើការធ្វើស្រែចំការ។ ស្រូវ ក៏ជាទំនិញនាំចេញដ៏មានសារៈសំខាន់មួយរបស់ប្រទេសកម្ពុជា ផងដែរ។ នៅក្នុងកំឡុងទស្សវត្សឆ្នាំ ១៩៦០ ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលដើរតួនាទីជាប្រទេសនាំស្រូវចេញយ៉ាងសំខាន់មួយនៅលើពិភពលោក។ ក៏ប៉ុន្តែ ដោយសារតែប្រទេសជាតិបានលិចលង់ទៅក្នុងសង្គ្រាមស៊ីវិល និងជំលោះផ្ទៃក្នុងផលិតកម្មស្រូវបានធ្លាក់ចុះហើយប្រទេសកម្ពុជាបានប្រែក្លាយជាប្រទេសនាំអង្ករចូលវិញ។ ចាប់តាំងពីប្រទេសទទួលបានសន្តិភាព និងមានស្ថេរភាពនយោបាយមកជាពិសេសនៅកំឡុងចុងទស្សវត្សឆ្នាំ ៩០ និងដើមឆ្នាំ ២០០០ ផលិតកម្មស្រូវមានកំណើនគួរអោយចាប់អារម្មណ៍។ ឧទាហរណ៍ នៅរដូវឆ្នាំ ២០០៧-២០០៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានរាយការណ៍ថា ប្រទេសកម្ពុជាផលិតស្រូវបាន ៦.៧ លានតោនស្រូវ[៣] ( មានការកើនឡើងចំនួន ៥០% បើប្រៀបធៀបទៅនឹងកំឡុងឆ្នាំ ១៩៩៧-១៩៩៨)[៤] ហើយផលិតផលស្រូវសល់ជាង ២.៥ លានតោនស្រូវ។ ទំនោរនៃការកើនឡើងនៃផលិតកម្មស្រូវនេះ ជាមួយនឹងការកើនឡើងនៃតម្លៃអង្ករនៅលើទីផ្សារពិភពលោក ផ្តល់នូវឱកាសយ៉ាងសំខាន់ថ្មីមួយសម្រាប់កសិករជាអ្នកធ្វើស្រែ និងសេដ្ឋកិច្ចជាតិ។ កាលពីពេលថ្មីៗនេះ រដ្ឋាភិបាលកម្ពុជាបានប្រកាសថាប្រទេសកម្ពុជាមានផែនការពង្រីកការដាំដុះស្រូវដើម្បីការនាំចេញរហូតដល់ទៅ ៨ លានតោន នៅឆ្នាំ ២០១៥។[៥] អត្ថបទនេះ ពិភាក្សាអំពីសក្តានុពលនៃផ្នែកស្រូវក្នុងប្រទេសកម្ពុជា និងវិធីដែលប្រទេសកម្ពុជាអាចប្រើប្រាស់សក្តានុពលនេះសម្រាប់ជាប្រយោជន៍ដល់គ្រួសារកសិករ

---

១: អង្គការសេដាក ឬ មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

២: លោកបណ្ឌិត យ៉ង សាំងកុមារ គឺជាប្រធានអង្គការសេដាក, yskoma@online.com.kh

៣: សន្ទរកថារបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម នៅសិក្ខាសាលាប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម ( ថ្ងៃទី ២-៣ មេសា ២០០៨)

៤: ក្រសួងកសិកម្ម ( ស្ថិតិប្រចាំឆ្នាំ ១៩៩៧-៩៨)

៥: កាសែត មេគង្គថែម ថ្ងៃ ២៥-២៧ ខែ មេសា ឆ្នាំ ២០០៨

និងសេដ្ឋកិច្ចជាតិនៅលើមូលដ្ឋាននិរន្តរភាព ជាពិសេសតាមរយៈការជំរុញនូវប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ ។

## ២. កម្មវិធីប្រពលវប្បកម្មស្រូវដែលមាននៅប្រទេសកម្ពុជា

ប្រទេសកម្ពុជាមានផ្ទៃដីសរុបចំនួន ១៨១ ០៣៨ គ.ម$^{២}$ និងប្រជាជនសរុបប្រមាណជា ១៤ លាននាក់ នៅឆ្នាំ ២០០៨។ ផ្ទៃដីកសិកម្មសរុបប្រមាណ ៣.១ លានហិកតា ខណៈពេលដែលផ្ទៃដីដែលមានលក្ខណៈសមស្របសំរាប់កសិកម្មទាំងអស់មានច្រើនជាងពីរដងនៃចំនួននេះគឺ ៦.៧ លានហិកតា។ បើធ្វើការប្រៀបធៀបទៅនឹងប្រទេសនាំចេញអង្ករដ៏ធំក្បែរខាងខ្លួនដូចជា ប្រទេសថៃ និងប្រទេសវៀតណាម ប្រទេសកម្ពុជាមានសក្តានុពលសម្រាប់កសិកម្មច្រើន បើគេគិតពីដង់ស៊ីតេប្រជាជន និងផ្ទៃដីកសិកម្ម។

យោងតាមទិន្នន័យដែលបានមកពីក្រសួងកសិកម្ម ផ្ទៃដីកសិកម្មសំរាប់ដំណាំស្រូវនៅរដូវឆ្នាំ ២០០៧-២០០៨ មានចំនួន ២.៥៨ លានហិកតា គឺប្រមាណជា ៨៣ % នៃផ្ទៃដីកសិកម្មសរុប។

ដំណាំស្រូវ ត្រូវបានដាំ ឬធ្វើនៅក្នុងពីររដូវផ្សេងគ្នាដូចខាងក្រោមៈ

- រដូវវស្សាៈ ជាមួយនឹងផ្ទៃដីប្រមាណជា ៨៥% នៃផ្ទៃដីធ្វើស្រែសរុប ហើយផលិតផលស្រូវភាគច្រើនអាស្រ័យលើទឹកភ្លៀង។
- រដូវប្រាំងៈ ផ្ទៃដីប្រមាណជា ១៥ % នៃផ្ទៃដីធ្វើស្រែសរុប ដែលភាគច្រើនជាស្រូវប្រដេញទឹក (ក្រោយទឹកបឹង ទន្លេ ស្រក)។

ទិន្នផលស្រូវជាមធ្យមនៅក្នុងរដូវវស្សាគឺ ២.៤០ តោនក្នុងមួយហិកតា ខណៈពេលដែលទិន្នផលស្រូវប្រាំងមានចំនួន ៣.៩៦ តោនក្នុងមួយហិកតា។ យោងតាមទិន្នន័យផ្លូវការពីក្រសួងកសិកម្ម[៦] បានឱ្យដឹងថា ទិន្នផលស្រូវនៅរដូវវស្សាបានកើនឡើងពីតិចជាង ២ តោនក្នុងមួយហិកតា នៅឆ្នាំ ១៩៩០ ទៅច្រើនជាង ២ តោនក្នុងមួយហិកតានៅឆ្នាំ ២០០០ នៅពេលដែលទិន្នផលស្រូវនៅរដូវប្រាំងការកើនឡើង ពីតិចជាង ៣ តោនក្នុងមួយហិកតា ទៅច្រើនជាង ៣ តោនក្នុងមួយហិកតានៅឆ្នាំ ២០០០ ។ ការកើនឡើងនៃទិន្នផលស្រូវ គឺមួយផ្នែកដោយសារការកើនឡើងនៃការប្រើប្រាស់ជីគីមី និងពូជកែលំអ និងការបណ្តុះបណ្តាល ផ្សព្វផ្សាយកសិកម្ម

---

៦: ស្ថិតិប្រចាំឆ្នាំ របស់ក្រសួងកសិកម្ម ពីឆ្នាំ ១៩៩៧-១៩៩៣ ទៅ ២០០៦-២០០៧

ដែលបានអនុវត្តនិងគាំទ្រដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និង គម្រោងអភិវឌ្ឍន៏ ភ្នាក់ងារផ្តល់ជំនួយទ្វេភាគី និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើនទៀត។

ចរន្តនៃការជំរុញប្រពលវប្បកម្មស្រូវកន្លងមក (លើកលែងតែកម្មវិធីវិធានការណ៏ដើម្បីការពារដំណាំ (IPM) និងកម្មវិធីកសិកម្មប្រកបដោយនិរន្តភាពខ្លះ) ច្រើនផ្តោតសំខាន់លើការកើនឡើងនៃការប្រើប្រាស់វត្ថុធាតុពីខាងក្រៅ ពិសេសគឺពូជថ្មី ឬពូជកែលំអ និងការណែនាំអោយប្រើប្រាស់ជីគីមី។ ជាលទ្ធផលយើងបានមើលឃើញថា ជាង ៨៥% នៃផ្ទៃដីស្រូវប្រាំងដែលត្រូវបានដាំដុះគឺប្រើពូជ អ៊ីរ៉េ (IR) ពិសេសគឺ អ៊ីរ៉េ ៦៦។ ទោះជាយ៉ាងណាក៏ដោយ នៅរដូវវស្សា កសិករភាគច្រើននៅតែប្រើពូជស្រូវបុរាណរបស់គេ លើកលែងតែស្រូវដើមរដូវវស្សា (ដែលមានដាំនៅលើផ្ទៃដីតិចជាង ១០ ភាគរយ) ដែលកសិករប្រើពូជអ៊ីរ៉េ ដោយមានរយៈពេលខ្លី និងជារូបភាពប្រពលវប្បកម្ម។ ជារួមការធ្វើប្រពលវប្បកម្មតាមបែបបដិវត្តន៏បៃតងត្រូវបានអនុវត្តភាគច្រើន នៅស្រូវរដូវប្រាំង។

នៅឆ្នាំ ២000 អង្គការសេដាកបានចាប់ផ្តើមណែនាំនូវ **ប្រពលវប្បកម្មស្រូវតាមបែបថ្មីមួយ** ដែលត្រូវបានគេស្គាល់ថា **ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៏ធម្មជាតិ ឬ ប.វ.ស**។ ក្នុងកំឡុងឆ្នាំ ណែនាំដំបូងមានកសិករចំនួនតែ ២៨ នាក់ប៉ុណ្ណោះ ដែលបានរៀបចំសាកល្បងអនុវត្តនូវគំនិតថ្មី ប.វ.ស នេះ ប៉ុន្តែចំនួនកសិករ ប.វ.សបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលមានចំនួនច្រើនជាង ៨២ 000 នាក់នៅឆ្នាំ ២00៧[៧] ដែលក្នុងនោះ មានកសិករប្រមាណចំនួន ៦0 000 បានទទួលការគាំទ្រដោយផ្ទាល់ពី អង្គការសេដាក។ ចំនួននេះ ត្រូវបានរំពឹងថានឹងកើនឡើងលើស ១00 000 នាក់នៅឆ្នាំ ២00៨ ។ គួរកត់សម្គាល់ថា កត្តាមួយក្នុងចំណោមកត្តាសំខាន់ៗជាច្រើនដែលនាំឱ្យមានការកើនឡើងនូវចំនួនកសិករអនុវត្តន៏នូវប.វ.ស គឺភាពដឹកនាំរបស់ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិសេសចាប់តាំងពីឆ្នាំ ២00៥ មក។ ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន គឺជាតួអង្គរដ្ឋាភិបាលសំខាន់មួយទៀតដែលជួយជំរុញ ប.វ.ស ចាប់តាំងពីលោកបានចូលរួមនៅក្នុងពិធីចែករង្វាន់ លើការគាំទ្រសហគ្រិនសម្រាប់ការអភិវឌ្ឍន៏ប្រកបដោយនិរន្តរភាព (SEED Award) នៅទីក្រុង ញូវយ៉ក ក្នុងខែមេសា ឆ្នាំ ២00៥

---

៧: លេខាធិការ ប.វ.ស (២00៨) របាយការណ៏ប.វ.សប្រចាំឆ្នាំ ២00៧

ដែលរៀបចំដោយ IUCN, UNDP និង UNEP ដែលអង្គការសេដាកជាអ្នកទទួលរង្វាន់នេះជាមួយវិទ្យាស្ថាន CIIFAD ។

**អ្វីទៅជា ប.វ.ស?**

ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស) គឺជាសំណុំនៃបច្ចេកទេស ឬការអនុវត្តល្អៗដែលបង្កើតឱ្យមានលក្ខណ្ឌល្អប្រសើរសម្រាប់ការលូតលាស់**ឫស និងដើម** ។ នៅពេលដែលឫសស្រូវមានការលូតលាស់ល្អ វានាំអោយស្រូវ នឹងមានដើមច្រើន កួរច្រើន និងគ្រាប់ច្រើនក្នុងកួរនីមួយៗ ។

មូលដ្ឋាននៃគំនិត ឬគោលការណ៍របស់ ប.វ.ស រួមមានៈ

- ប្រើប្រាស់តែសំណាបដែលមានសុខភាពល្អៈ សំណាបដើមថ្លោស និង**ខ្លី** សម្រាប់ស្ទូង ដោយប្រើនូវ **គ្រាប់ពូជដែលសុទ្ធ និងគ្រាប់ពេញល្អ** ដែលត្រូវបានយកទៅសាបនៅលើ **ថ្នាលសំណាបគោក** (ដែលមានទ្រង់ទ្រាយដូចទៅនឹងរងបន្លែដែរ)
- **ការទុកចន្លោះទូលាយ** រវាងដើមស្រូវនីមួយៗ គឺ**មួយដើម**ក្នុងមួយគុម្ព និងមាន**ចំងាយស្មើគ្នា**ចន្លោះពីគុម្ពមួយទៅគុម្ពមួយ
- ការស្ទូង**រាក់** (ជំរៅត្រឹមតែ ១-២ សង់ទីម៉ែត្រ)
- ធ្វើអោយ**ខ្យល់ចេញចូលក្នុងដី**បានល្អ ដោយជៀសវាងឱ្យស្រែមានទឹកលិចជាប់ជាប្រចាំ នៅដំណាក់កាលលូតលាស់ដំបូងរបស់ស្រូវ
- **ដកស្មៅ**អោយបានញឹកញាប់ ដើម្បីកុំឱ្យស្មៅដុះប្រណាំងជាមួយស្រូវ និងដើម្បីឱ្យដីមាន**ខ្យល់ ចេញចូល**បានល្អ
- បង្កើន**សារធាតុសរីរាង្គ**ទៅក្នុងដី តាមរយៈដីកំប៉ុស្ត ដែលជួយបង្កើននូវ**សកម្មភាពជីវសាស្ត្រ ឬ សកម្មភាពសត្វល្អិតរស់នៅក្នុងដី ។**

ដោយមើលឃើញនូវការកើនឡើងនូវទិន្នផល ជាមួយនឹងការថយចុះនូវតំរូវការគ្រាប់ពូជ ជីគីមី និងដែលជាការផ្តល់នូវផលចំណេញច្រើនជូនដល់កសិករ រាជរដ្ឋាភិបាលបានចាប់ផ្តើមជម្រុញជាផ្លូវការនូវគំនិត ប.វ.ស

នេះនៅឆ្នាំ ២០០៥។ បច្ចុប្បន្នគ្រប់មន្ទីរកសិកម្មនៅគ្រប់ខេត្តក្រុងទាំងអស់កំពុងតែពង្រីកការអនុវត្តន៍ ប.វ.ស នៅក្នុងកម្មវិធីស្រូវរបស់ពួកគេ។ យ៉ាងហោចណាស់ក៏មាន អង្គការក្រៅរដ្ឋាភិបាល និងគម្រោងអភិវឌ្ឍន៍ចំនួន ៤៧ ដែលកំពុងតែធ្វើការពាក់ព័ន្ធនឹងការជួយជម្រុញ ប.វ.ស ទៅតំបន់ផ្សេងៗទៀត នៃប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ ២០០៤ មកមានលេខាធិការដ្ឋាន ប.វ.ស ថ្នាក់ជាតិមួយ ដែលបានបង្កើតឡើងដោយនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មនៃក្រសួងកសិកម្ម ជាមួយនឹងការគាំទ្រ ផ្នែកបច្ចេកទេសពីអង្គការសេដាក និងឧបត្ថម្ភថវិកាពីអង្គការ GTZ, Oxfam អាមេរិក និង GB, FAO និង Heks (អង្គការក្រៅរដ្ឋាភិបាលមកពីប្រទេសស្វីស)។

យោងតាមទិន្នន័យដែលបានមកពីលេខាធិការដ្ឋាន ប.វ.ស ដែលមានមូលដ្ឋាននៅក្នុងក្រសួងកសិកម្ម កសិករចំនួន ៨២ ០០០ នាក់ ដែលធ្វើ ប.វ.ស កំពុងតែអនុវត្តគ្របដណ្ដប់នៅលើផ្ទៃដីចំនួនប្រមាណ ៤៧ ០០០ ហិកតា ស្មើនឹង ២.២% នៃផ្ទៃដីស្រូវវស្សាសរុប។ ជាមធ្យមពួកគេធ្វើបានទទួលផលប្រមាណ ៣.៥៦ តោនក្នុងមួយហិកតា ប្រមាណជា ១.១៦ តោនក្នុងមួយហិកតា ច្រើនជាងការធ្វើស្រែមិនមែនប.វ.ស។ បរិមាណនេះ គឺអាចផ្ដល់ជាអត្ថប្រយោជន៍បន្ថែមប្រមាណ ៥៤ ៥២០ តោនស្រូវក្នុងមួយឆ្នាំ សម្រាប់ប្រទេសកម្ពុជានៅឆ្នាំ ២០០៧ ដែលតម្លៃជាទឹកប្រាក់ស្មើនឹង ១១ លានដុល្លារសហរដ្ឋអាមេរិក (បើគិតតាមតម្លៃស្រូវនៅខែ ធ្នូ ឆ្នាំ ២០០៧)។ លើសពីនេះទៅទៀត កសិករ ប.វ.ស មានលទ្ធភាពអាចបន្ថយបរិមាណការប្រើប្រាស់ជីគីមីប្រមាណ ៥០% បើប្រៀបទៅនឹងការធ្វើតាមធម្មតា ដែលប្រើប្រាស់ជីស្មើទៅនឹង ៧៥ គីឡូក្រាមក្នុងមួយហិកតា។ ការកាត់បន្ថយការប្រើប្រាស់ជីក្នុងបរិមាណ ៣ ៥២៥ តោន វាស្មើទៅនឹង ១.៥ លានដុល្លារអាមេរិក[៨] ជាខ្ទង់ចំណូលបន្ថែមសម្រាប់កសិករ។ លើសពីនេះកសិករប.វ.ស សន្សំបានបរិមាណគ្រាប់ពូជ ៥៥ គីឡូក្រាម ក្នុងមួយហិកតា បើប្រៀបទៅនឹងកសិករធ្វើតាមទំលាប់។ បរិមាណគ្រាប់ពូជដែលសន្សំនេះបានបន្ថែមនូវស្រូវ ២៥៨៥ តោនស្រូវបន្ថែមទៀតដល់ការផ្គត់ផ្គង់ស្រូវជូនប្រជាជនខ្មែរដែលមានតម្លៃជាទឹកប្រាក់ស្មើនឹង ០.៥ លានដុល្លារអាមេរិក។ ដូច្នេះទឹកប្រាក់ចំណេញសរុបដែលបានទទួលក្នុងឆ្នាំ ២០០៧ គឺប្រមាណជា ១៣ លានដុល្លារអាមេរិក។

ការសិក្សាវាយតម្លៃឯករាជ្យមួយទៅលើឥទ្ធិពលរបស់ ប.វ.ស នៅក្នុងប្រទេសកម្ពុជា ដែលឧបត្ថម្ភដោយអង្គការ ជីធីហ្សិត នៃប្រទេសអាល្លឺមង់ (GTZ) នៅឆ្នាំ ២០០៤ បានសន្និដ្ឋានថា ប្រសិនបើកសិករខ្មែរ

---

៨: តំលៃជីក្នុងឆ្នាំ ២០០៧

ត្រឹមតែ ១០% អាចផ្ទេរផ្ទៃដីស្រែរបស់គេត្រឹមតែ ៤២% ធ្វើប.វ.ស ផលចំណេញសេដ្ឋកិច្ចចំពោះជាតិ អាចមានដល់ ៣៦ លានដុល្លារអាមេរិកប្រចាំឆ្នាំ ដែលជាហេតុផលមួយគ្រប់គ្រាន់សំរាប់អោយកម្ពុជាប្រើការ ពង្រីកការបណ្តុះបណ្តាលប.វ.ស នៅក្នុងប្រព័ន្ធពង្រីកកសិកម្មថ្នាក់ជាតិ ។[៩]

យោងតាមបទពិសោធន៍របស់កសិករឆ្នើម ដែលបានអនុវត្តត្រឹមត្រូវនូវគោលការណ៍ប.វ.ស ពួកគេអាចទទួល ទិន្នផលបានចាប់ពី ៧ ទៅ ៩ តោនស្រូវក្នុងមួយហិកតា (ច្រើនជាងពីរដងនៃទិន្នផលស្រូវប.វ.សជាមធ្យម នាពេលបច្ចុប្បន្ន) នៅក្រោមលក្ខ័ណ្ឌប្រើទឹកភ្លៀងនិងគ្រាប់ពូជក្នុងស្រុក ។[១០] ទិន្នផលនេះ បង្ហាញនូវ សក្តានុពលដ៏ធំមួយ នៅក្នុងការបង្កើនផលិតភាពស្រូវនៅក្នុងប្រព័ន្ធកសិកម្ម ដែលអាស្រ័យដោយទឹកភ្លៀង នៃប្រទេសកម្ពុជា ដែលជាតំបន់មានតម្រូវការសេដ្ឋកិច្ចសង្គមដ៏ខ្លាំង ។ ក្រៅពីអត្ថប្រយោជន៍សន្តិសុខស្បៀង និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ប.វ.ស បានកាត់បន្ថយនូវការប្រើប្រាស់ជីគីមីកសិកម្ម ដែលនាំឱ្យការបំពុលទឹក និងដីមានការថយចុះ ។ម្យ៉ាងវិញទៀត នៅពេលដែលផលិតផលស្រូវទទួលបានទិន្នផលខ្ពស់ក្នុងមួយឯកតាដី នោះអនុញ្ញាតឱ្យកសិករអាចប្រើប្រាស់ដីមួយចំណែកនៃដីស្រែសំរាប់ដាំបន្លែ ផ្លែឈើ ដើម្បីបង្កើននូវ របបអាហារ និងប្រាក់ចំណូល របស់ពួកគេ ហើយវាបញ្ចៀសសម្ពាធទៅលើតំបន់អេកូឡូស៊ីដែលត្រូវការពារ ។ ការអនុវត្តតាម ប.វ.ស ក៏អាចឱ្យកសិករខ្មែរទាញយកនូវផលចំណេញពីកម្មវិធីលក់សារធាតុកាបោន និង កម្មវិធីបរិស្ថានជាច្រើនផ្សេងទៀតដែលកំពុងត្រូវបានយកចិត្តទុកដាក់ ។

## ៣. យុទ្ធសាស្ត្រដើម្បីបង្កើនផលិតកម្មស្រូវ

មានសក្តានុពលដ៏ធំមួយសម្រាប់ការពង្រីកផលិតកម្មស្រូវនៅក្នុងប្រទេសកម្ពុជា ដោយសារតែផលិតភាព ស្រូវនៅពេលបច្ចុប្បន្ននៅមានកំរិតទាបនៅឡើយ និងលទ្ធភាពក្នុងការពង្រីកផ្ទៃដីកសិកម្មបន្ថែម ។ ជាទូទៅ គេអាចបង្កើនការដាំដុះបានពីរដងនៅលើផ្ទៃដីប្រមាណជា ៤០% នៃផ្ទៃដីស្រែ ក្នុងរដូវវស្សារបៀបជាស្រូវ ដើមរដូវវស្សា (អាស្រ័យលើទឹកភ្លៀង) និងស្រូវចុងរដូវវស្សា ។ ដើម្បីប្រើប្រាស់ សក្តានុពល ដែលមានស្រាប់នេះឱ្យបានទូលំទូលាយ យុទ្ធសាស្ត្រខាងក្រោមនេះ ត្រូវបានស្នើជូនរដ្ឋាភិបាល ម្ចាស់ជំនួយ អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ យកទៅពិចារណាសំរាប់ការអនុវត្តន៍:

---

៩: អេនសូហ្វី ដូអើជិន អេ អាល់ (២០០៤)

១០: អង្គការសេដាក (២០០៨) របាយការណ៍ស្តីអំពីពានរង្វាន់ឆ្នើមសម្រាប់កសិករ ប.វ.ស ឆ្នាំ ២០០៧

១. ការអនុវត្តន៏ និងការគាំទ្រដល់កម្មវិធីផ្សព្វផ្សាយ ប.វ.ស ដែលធានាថាកសិករទាំងអស់នៅក្នុងប្រទេសកម្ពុជាអាចរៀនអំពីគំនិតប.វ.ស និងអាចអនុវត្តគំនិតទាំងនេះអោយសមស្របទៅតាមលក្ខណៈពិសេសរបស់តំបន់គេ ដើម្បីបង្កើននូវផលិតកម្មស្រូវរបស់ពួកគេ។ យើងអាចជម្រុញ ប.វ.ស បានតាមរយៈកសិករបង្គោល នៅតាមភូមិឃុំទូទាំងប្រទេសកម្ពុជា។ បច្ចុប្បន្នមានកសិករដែលមានសមត្ថភាពនិងចង់ចូលរួម នៅក្នុងកម្មវិធីដូចខាងលើនៅស្ទើរគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។ កសិករបង្គោលគួរតែគាំទ្រអោយធ្វើការពិសោធន៏ ឬបង្ហាញនិងធ្វើការបណ្តុះបណ្តាលបន្តដល់កសិករដទៃអោយបានគ្រប់ភូមិ ដែលមានអ្នកធ្វើស្រែតាមវិធីសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករ។ ដើម្បីអនុវត្តនូវសកម្មភាពនេះ វាទាមទារឱ្យមានប្រាក់ពី ៥-៦ លានដុល្លារ អាមេរិកក្នុងមួយឆ្នាំ សម្រាប់រយៈពេល ៥ ទៅ ៨ ឆ្នាំ (បរិមាណនេះ គឺតិចជាង ២% នៃជំនួយអភិវឌ្ឍន៏ដែលមានស្រាប់ ដែលត្រូវបានផ្តល់ដល់ប្រទេសកម្ពុជា ជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៩៣ មក)។

២. ការអនុវត្តន៏ និងការគាំទ្រដល់កម្មវិធី ការជ្រើសរើសពូជស្រូវនៅតាមសហគមន៏អោយបានទូទាំងប្រទេស ដើម្បីធានាថា កសិករទាំងអស់បានឈានដល់ការទទួលបាននូវគ្រាប់ពូជដែលមានគុណភាពល្អ និងដែលមានលក្ខណៈសមស្របសំរាប់តំបន់របស់គេ។ គេអាចអនុវត្តសកម្មភាពនេះតាមរយៈការជ្រើសរើសកសិករមួយចំនួននៅក្នុងភូមិនីមួយៗ ដើម្បីទទួលការបណ្តុះបណ្តាល និងចាប់ជំនាញជាអ្នកផលិតគ្រាប់ពូជនៅក្នុងសហគមន៏។ យើងអាចជ្រើសរើសពូជទំនើបមកដាក់ចូលនៅក្នុងកម្មវិធីនេះ ក៏ប៉ុន្តែដោយពូជប្រពៃណីក៏អាចផ្តល់នូវផលខ្ពស់តាមរយៈប.វ.ស គេគួររាប់បញ្ចូលពូជប្រពៃណី ក្នុងកម្មវិធីផលិតពូជតាមសហគមន៏ផងដែរ។

៣. ជម្រុញកម្មវិធីគ្រប់គ្រងជីជាតិដីនៅទូទាំងប្រទេស ពិសេសការជម្រុញការដាំដុះជីស្រស់នៅកំឡុងដើមរដូវវស្សា ការដាំដុះ និងប្រើប្រាស់នូវដើមឈើដែលអាចរីកលូតលាស់លឿនហើយផ្តល់នូវសារធាតុអាសូត សំរាប់យកស្លឹកមកប្រើជាជីធម្មជាតិ ឬប្រើប្រាស់ជីកំប៉ុស្ត។ គេអាចធ្វើសកម្មភាពនេះ ជាមួយនឹងកម្មវិធីពង្រីក ប.វ.ស ជាពិសេសនៅកន្លែងណាដែលកសិករពិបាករកវត្ថុធាតុដើម ឬសារធាតុសេរីរាង្គសំរាប់យកមកធ្វើជាជីកំប៉ុស្ត។

៤. ការអភិវឌ្ឍន៏ប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងមធ្យម និងការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម ពិសេសសម្រាប់ស្រោចស្រព្វបន្ថែមនៅរដូវវស្សា។ ការអនុវត្តតាមប.វ.ស កាត់បន្ថយ

នូវតម្រូវការទឹកស្រោចស្រព ហើយគេអាចទទួលបានទិន្នផលស្រូវកាន់តែខ្ពស់តាមរយៈការកែលំអការគ្រប់គ្រងទឹក ដោយប្រើការស្រោចស្រប់ទឹកនៅក្នុងបរិមាណតិចតែទៀងទាត់។ ដូច្នេះការវិនិយោគនូវប្រព័ន្ធធារាសាស្ត្រអាចនាំមកនូវផលចំណេញជាច្រើន។ កម្មវិធីនេះអាចទាក់ទាញអ្នកផ្តល់ជំនួយអភិវឌ្ឍន៍ដែលចង់ជួយជម្រុញនូវសន្តិសុខស្បៀង និងការលប់បំបាត់នូវភាពក្រីក្រដើម្បីបង្កើនការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ។

៥. រៀបចំអោយសិប្បកម្មក្នុងស្រុកដើម្បីផលិតនូវឧបករណ៍សមស្របសំរាប់ជួយដល់ផលិតកម្មស្រូវតាមរបៀប ប.វ.ស ជាពិសេសឧបករណ៍សំរាប់ធ្វើស្មៅបំផុសដី ឧបករណ៍សម្រាប់ជួយក្នុងការស្ទូង និងឧបករណ៍ផ្សេងៗទៀត ដែលអាចជួយ និងកាត់បន្ថយនូវការប្រើប្រាស់កម្លាំងពលកម្ម។ សហគ្រាសក្នុងស្រុកដែលធ្វើលើបញ្ហានេះ អាចបង្កើននូវការងារក្នុងស្រុក និងបង្កើននូវផលិតភាពពលកម្ម និងប្រាក់ចំណូល។

៦. ការបង្កើននូវសមត្ថភាព កិន ស្តុកស្រូវទុក ការផ្សារភ្ជាប់កសិករមកទីផ្សារឱ្យកាន់តែប្រសើរ។

ការអនុវត្តផ្តុំចូលគ្នានូវយុទ្ធសាស្ត្រដែលបានលើកឡើងខាងលើ នឹងអាចធ្វើឱ្យកសិករអាចបង្កើនទិន្នផលរបស់ពួកគេប្រមាណជា ៣ ទៅ ៤ តោនក្នុងមួយហិកតានៅរដូវវស្សា។ ការអនុវត្តន៏នូវយុទ្ធសាស្ត្រទី ៤ នឹងធ្វើឱ្យយើងអាចពង្រីកផ្ទៃដីកសិកម្មនៅដើមរដូវវស្សាប្រហែលជា ០.៨ លានហិកតា។ យុទ្ធសាស្ត្រទាំងនេះប្រសិនបើអនុវត្តបានដោយជោគជ័យ នឹងធ្វើឱ្យកសិករកម្ពុជា ផលិតបានផលស្រូវប្រមាណ ១២ ទៅ ១៣ លានតោនក្នុងមួយឆ្នាំ ឬប្រមាណជា ៤០០០ ទៅ ៥០០០ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ។[១១] បរិមាណនេះប្រមាណជាពីរដងនៃកំរិតបរិមាណផលិតកម្មបច្ចុប្បន្ន ហើយអាចសល់បានប្រមាណ ៧ ទៅ ៨ លានតោនស្រូវក្នុងមួយឆ្នាំ (៤.៥ លានតោនអង្ករ ឬ ៣០០០ លានដុល្លារប្រចាំឆ្នាំ)។ ចំនួននេះអាចអនុញ្ញាតឱ្យប្រទេសកម្ពុជាក្លាយជាប្រទេស នាំចេញស្រូវធំជាងគេទីពីរ ឬទីបី ក៏ដូចជាអាចចូលរួមចំណែកដល់ការធានានូវសន្តិសុខស្បៀងពិភពលោក។

ដើម្បីទទួលបានអត្ថប្រយោជន៏បន្ថែមពីការនាំចេញស្រូវ ប្រទេសកម្ពុជាត្រូវការអភិវឌ្ឍន៏បន្ថែម និងប្រសើរជាងមុននូវសមត្ថភាពស្តុកស្រូវទុក និងកិនស្រូវដែលខ្លួនមាននាពេលបច្ចុប្បន្ន (យុទ្ធសាស្ត្រទី ៦ ដែលបានស្នើឡើង)។ កម្ពុជាក៏ត្រូវតែរៀបចំខ្លួនឱ្យប្រសើររសម្រាប់នាំចេញអង្ករដោយផ្ទាល់ ជាជាងការពឹងទៅលើការ

---

១១: តម្លៃនៅដើមខែ មិថុនា ឆ្នាំ ២០០៨

នាំចេញស្រូវក្រៅផ្លូវការ និងមិនមានការគ្រប់គ្រងច្បាស់លាស់ដូចពេលបច្ចុប្បន្ន។ ការនាំចេញអង្ករដោយផ្ទាល់នឹងបង្កើតការងារបន្ថែមនៅក្នុងស្រុក ហើយនឹងអាចផ្តល់នូវ អង្កាម និងកន្ទក់ យ៉ាងច្រើនក្រៃលែងដើម្បីប្រើប្រាស់នៅក្នុងស្រុក ជាពិសេសសម្រាប់ការចិញ្ចឹមសត្វ និងការបង្កើនជីជាតិដី។ លើសពីនេះទៅទៀត ប្រសិនបើមានការរៀបចំឱ្យបានប្រសើឡើងនូវការងារទីផ្សារ ប្រេងកន្ទក់នឹងក្លាយជាផលិតផលដែលមានតម្លៃខ្ពស់ ដែលអាចធ្វើការនាំចេញ ដោយសារការអោយតម្លៃទៅលើអត្ថប្រយោជន៏សុខភាពរបស់វាមានការកើនឡើងគួរអោយចាប់អារម្មណ៏ (http://www.ricebranoil.info)។

យុទ្ធសាស្ត្រដូចមានរាយជូនខាងលើ ដើម្បីបង្កើនផលិតកម្មស្រូវតាមរយៈវិធីសាស្ត្រ ប.វ.ស ត្រូវទាមទារនូវតួនាទីដឹកនាំដោយរដ្ឋាភិបាល ហើយយុទ្ធសាស្ត្រទី ៥ អាចទុកឱ្យផ្នែកឯកជន ដោយគ្រាន់តែត្រូវការនូវគំនិតផ្តួចផ្តើមពីរដ្ឋាភិបាលតិចតួច។ ការអភិវឌ្ឍន៏ទីផ្សារ ការកិន និងការស្តុកស្រូវ យកល្អប្រហែលជាអាចត្រូវផ្តល់ជូនទៅឱ្យផ្នែកឯកជន សហគមន៏កសិករ ឬអង្គការកសិករ ឬក្រុមហ៊ុនជាអ្នកអនុវត្ត វាអាចជោគជ័យប្រសើរជាង ក៏ប៉ុន្តែវាអាចមានភាពជោគជ័យច្រើនជាងប្រសិនបើរដ្ឋាភិបាលមានគោលនយោបាយគាំទ្រ ដែលបង្កលក្ខណៈអំណោយផលដល់ការវិនិយោគដ៏សមស្រប។